


# We're developing a new vision for the 710 corridor.

I-710 TASK FORCE

Metro

# សូមស្វាគមន៍!

*យើងនឹងចាប់ផ្តើមនៅពេលបន្តិចទៀត។*

**កិច្ចប្រជុំក្រុមការងារផ្លូវលេខ 710 #9៖**

ថ្ងៃទី13 ខែឧសភា ឆ្នាំ2022

Metro

# អ្នកសម្របសម្រួល



**Erika C.B. Morales**

Partner, Morales + Morales Partners

Metro

# ក្រុមការងារ Metro



**KeAndra Cylear Dodds**

LA Metro, Equity and Race



**Ernesto Chaves**

LA Metro, Highway Programs



**Jessica Medina**

LA Metro, Equity and Race



**Lilian De Loza-Gutierrez**

LA Metro, Community Relations



**Michael Cano**

LA Metro, Countywide Planning

Metro

# Interpretation/*Interpretación/kar bakasray/Interpretasyon*

**To listen to the meeting in another language:**

***Español*:**

> *Llamada en español:* 872.240.3212
> *Código de acceso:* 514-659-501

***Khmer:***

> *សេចក្តីលម្អិត អំពីការហៅចូលប្រជុំ:* 786.535.3211
> *លេខកូដចូលប្រើ:* 856-303-189

***Tagalog:***

> *Mga Detalye sa Call-in sa Pagpupulong:* 872.240.3212

> *Kodigo:* 933-864-189

**Tech Support - Google phone line/text**

> Phone: 323.609.3345
> Monitoring, translation support

Metro

# Task Force Member Identification

**Task Force Members, please change your Zoom screen name to include:** Name and Organization Name




Metro

# Raise Hand/លើកដៃ

> Click **Raise Hand** in your meeting controls or

> **Press*9** on the phone line.

> To lower your hand, click **Raise Hand** in your meeting controls.

> Comments & questions can also be provided in writing by using the **Q&A** function.

> The **Q&A** button is located on the control panel at the bottom of your screen.

> If you're listening in on our Spanish, Khmer or Tagalog **phone** call-in lines and have a question or comment, please **press *6** to unmute yourself and let the interpreter know.

> សូមចុចលើពាក្យ **Raise Hand (លើកដៃ)** នៅក្នុងផ្ទាំងកម្មវិធីគ្រប់គ្រងការប្រជុំរបស់អ្នក ឬ

> **ចុច *9** នៅលើខ្សែទូរស័ព្ទ។

> ដើម្បីដាក់ដៃរបស់អ្នកចុះ សូមចុចពាក្យ Raise Hand **(លើកដៃ)** នៅក្នុងផ្ទាំងកម្មវិធីគ្រប់គ្រងការប្រជុំរបស់អ្នក។

> យោបល់ & សំណួរ ក៏អាចផ្តល់ឱ្យជាលាយលក្ខណ៍អក្សរ ដោយប្រើមុខងារ **Q&A (សំណួរ & ចម្លើយ)**។

> ប៊ូតុង **Q&A (សំណួរចម្លើយ)** មានទីតាំងស្ថិតនៅលើផ្ទាំងបញ្ជានៅផ្នែកខាងក្រោមនៃអេក្រង់របស់អ្នក។

> ប្រសិនបើអ្នកស្តាប់ខ្សែ**ទូរសព្ទ**ហៅចូលជាភាសាអេស្ប៉ាញ ខ្មែរ ឬតាហ្គាឡុករបស់យើង ហើយមានសំណួរ ឬមតិយោបល់ សូម**ចុច *6** ដើម្បីបើកសំឡេងខ្លួនឯង ហើយប្រាប់អ្នកបកប្រែឱ្យដឹង។

# សូមស្វាគមន៍!

# វត្ថុបំណងនៃកិច្ចប្រជុំ

- ក្រុមការងារដែលត្រូវទទួលយកការបោះឆ្នោតសម្រេចនៅលើសំណើសេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ គោលការណ៍ដឹកនាំ គោលដៅសម្រាប់ខ្សែផ្លូវ I-710 ភាគខាងត្បូង

- ធ្វើបច្ចុប្បន្នភាពព័ត៌មានលើសកម្មភាពភាពក្រុមប្រឹក្សាភិបាល Metro នៅកិច្ចប្រជុំខែឧសភា ឆ្នាំ2022 រួមទាំងការអនុម័តលើជម្រើស "No Build (គ្មានការសាងសង់)" សម្រាប់គម្រោងខ្សែផ្លូវ I-710 ភាគខាងត្បូង និងសំណើដោយអភិបាល Hahn, Solis, Mitchell, និង Dutra ស្តីពីរបៀបជំរុញការងាររបស់ក្រុមការងារឱ្យរីវឌ្ឍឆ្ពោះទៅមុខ។

- ណែនាំអំពីជំហានបន្ទាប់នៃគម្រោងនេះ

- រាយការណ៍លម្អិតពីក្រុមការងារគម្រោង ក្រុមការងារផ្សេងៗ និងគណៈកម្មាធិការដឹកនាំសហគមន៍ និងគណៈកម្មាធិការសម្របសម្រួល

- ការបញ្ជាក់របស់សមាជិកគណៈកម្មាធិការដឹកនាំសហគមន៍ថ្មី

Metro

# របៀបវារៈ

| | |
|---|---|
| 5:00 ល្ងាច | ការស្វាគមន៍ ការណែនាំឱ្យស្គាល់ ការពិនិត្យមើលរបៀបវារៈ និងវត្ថុបំណងអង្គប្រជុំ |
| 5:20 ល្ងាច | របៀបវារៈ #1៖ សំណើសេចក្តីព្រាងសេចក្តីថ្លែងចក្ខុវិស័យ គោលការណ៍ណែនាំ & គោលដៅសម្រាប់តំបន់ខ្សែ ផ្លូវ 710 |
| 6:55 ល្ងាច | របៀបវារៈ #2៖ បច្ចុប្បន្នភាពក្រុមការងារគម្រោង |
| 7:10 ល្ងាច | របៀបវារៈ #3៖ រាយការណ៍លម្អិត (ប្រសិនបើមានពេលវេលាគ្រប់គ្រាន់) |
| 7:25 យប់ | មតិយោបល់សាធារណៈទូទៅ និងសុន្ទរកថាបិទបញ្ចប់ |
| 7:30 យប់ | ការប្រជុំនាពេលខាងមុខ |

Metro

# របៀបវារៈលម្អិត

**5:00 ល្ងាច  មតិស្វាគមន៍ ការណែនាំឱ្យស្គាល់ ការពិនិត្យមើលរបៀបវារៈ និង**

**វត្ថុបំណងកិច្ចប្រជុំ វត្តមានចូលរួម** (20នាទី)

**5:20 ល្ងាច  របៀបវារៈ #1៖ សំណើសេចក្តីព្រាងនៃគោលការណ៍ដឹកនាំ សេចក្តីថ្លែងចក្ខុវិស័យ & គោលដៅសម្រាប់តំបន់ខ្សែផ្លូវ I-710 ភាគខាងត្បូង** (95នាទី)

- 1.1 ការសង្ខេបចំណុចសំខាន់នៃមតិចូលរួមដែលទទួលបាន (5នាទី)
- 1.2 សមធម៌ និងនិរន្តរភាពសម្រាប់ជាគោលការណ៍ដឹកនាំ (5នាទី)
  - i. កិច្ចពិភាក្សា (10នាទី)
  - ii. និរន្តរភាពសម្រាប់ជាគោលការណ៍ដឹកនាំ - ការសាកល្បងសម្រាប់មតិរួម (5នាទី)
  - iii. មតិយោបល់សាធារណៈ (5នាទី)
  - iv. ការបោះឆ្នោត (5នាទី)
- 1.3 សេចក្តីថ្លែងចក្ខុវិស័យ (5នាទី)
  - i. កិច្ចពិភាក្សា (10នាទី)
  - ii. ការសាកល្បងសម្រាប់មតិរួម (5នាទី)
  - iii. មតិយោបល់សាធារណៈ (5នាទី)
  - iv. ការបោះឆ្នោត (5នាទី)
- 1.4 គោលដៅ (5នាទី)
  - i. កិច្ចពិភាក្សា (10នាទី)
  - ii. ការសាកល្បងសម្រាប់មតិរួម (5នាទី)
  - iii. មតិយោបល់សាធារណៈ (5នាទី)
  - iv. ការបោះឆ្នោត (5នាទី)

**6:55 ល្ងាច  របៀបវារៈ #2៖ បច្ចុប្បន្នភាពក្រុមការងារគម្រោង** (15នាទី)

- 2.1 បច្ចុប្បន្នភាពស្តីពីជម្រើសគ្មានការសាងសង់/សំណើផ្លូវ I-710 ថ្មីភាគខាងត្បូង (5នាទី)
  - i. ការរាយការណ៍ស្តីពីសេចក្តីថ្លែងចក្ខុវិស័យ គោលការណ៍ដឹកនាំ & គោលដៅ
  - ii. ការដាក់ឈ្មោះផ្លូវឡើងវិញ
  - iii. ការបង្កើតគម្រោងវិនិយោគដើមដំបូង
- 2.2 ជំហានបន្ទាប់នៃគម្រោង (ជំហាន III/IV)
  - i. កិច្ចពិភាក្សា (5នាទី)
  - ii. មតិយោបល់សាធារណៈ (5នាទី)

**7:10 យប់  របៀបវារៈ #3៖ រាយការណ៍លម្អិត (ប្រសិនបើមានពេលវេលាគ្រប់គ្រាន់)** (15នាទី)

- 3.1 កិច្ចប្រជុំ/ការតម្រង់ទិសរបស់គណៈកម្មាធិការដឹកនាំសហគមន៍ #3
  - i. ការបញ្ជាក់អំពីសមាជិក CLC ថ្មី
    - a. សំណើ
    - b. ការបោះឆ្នោត
- 3.2 កិច្ចប្រជុំក្រុមការងារ #8
- 3.3 កិច្ចប្រជុំក្រុមការងាររថយន្តដឹកទំនិញមិនបញ្ចេញផ្សែងពុល #6
- 3.4 ក្រុមការងារសមធម៌ #3
- 3.5 កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល #2

**7:25 យប់  មតិយោបល់សាធារណៈទូទៅ និងសុន្ទរកថាបិទបញ្ចប់** (5នាទី)

**7:30 យប់  កិច្ចប្រជុំខាងមុខ** (5នាទី)

Metro






Find more project materials at: https://www.metro.net/projects/i-710-corridor/#documents




Find more project materials at: https://www.metro.net/projects/i-710-corridor/#documents

# វត្តមានចូលរួមរបស់ក្រុមការងារ – ការហៅឈ្មោះ

| | ទីភ្នាក់ងារ | ដឹកនាំ | ជំនួស |
|---|---|---|---|
| 1 | Access Services, Inc. | Randy Johnson | Louis Burns |
| 2 | Alameda Corridor Transportation Authority (ACTA) | Michael Leue | |
| 3 | Breathe Southern California | Tigran Agdaian | Ivan Fonseca |
| 4 | Burlington Northern Santa Fe (BNSF) Railway | Lena Kent | |
| 5 | California Air Resources Board (CARB) | Robert Krieger | |
| 6 | CALSTART | Alycia Gilde | Niki Okuk |
| 7 | City of Bell Gateway Cities Council of Governments (GCCOG) Ad Hoc Committee | Councilmember Ali Saleh | |
| 8 | City of Commerce GCCOG Ad Hoc Committee | Mayor Oralia Rebollo | |
| 9 | City of Cudahy GCCOG Ad Hoc Committee | Mayor Elizabeth Alcantar | |
| 10 | City of Long Beach | Councilmember Suely Saro | |
| 11 | City of Los Angeles | Dan Rodman | Chet Edelman |
| 12 | Coalition for Clean Air | Chris Chavez | Commissioner Joe Lyou |
| 13 | Communities for a Better Environment (CBE) | Jennifer Ganata & Dilia Ortega *(co-leads)* | Ambar Rivera |
| 14 | County of Los Angeles, Supervisorial District 1 | Martin Reyes/Ben Feldman | Aydin Pasebani |
| 15 | County of Los Angeles, Supervisorial District 2 | Lilly O'Brien-Kovari | |
| 16 | County of Los Angeles, Supervisorial District 4 | Luke Klipp | Viviana Gomez |
| 17 | Earthjustice | Fernando Gaytan | Adrian Martinez |
| 18 | East Yard Communities for Environmental Justice (EYCEJ) | Laura Cortez | Taylor Thomas |
| 19 | Harbor Trucking Association (HTA) | Matt Schrap | Robert Loya |
| 20 | International Brotherhood of Teamsters, Local Union 848 | Eric Tate | Louie Diaz |
| 21 | LA County Business Federation (BizFed) | Chris Wilson | Sarah Wiltfong, Director of Policy |
| 22 | LA County Department of Public Works | Steve Burger | Elaine Kunitake/Edel Vizcarra |
| 23 | LA County Economic Development Corporation (LAEDC) | Stephen Cheung | |
| 24 | LA Unified School District | Fidencio Gallardo | |
| 25 | Legal Aid Foundation of LA-Long Beach (LAFLA-LB) | Ghirlandi Guidetti | Angela M. Turner |
| 26 | Long Beach Alliance for Children with Asthma (LBACA) | Sylvia Betancourt | Marlin Dawoodjee Vargas |
| 27 | Long Beach Transit (LBT) | Marisol Barajas | Lisa Patton |
| 28 | METRANS Transportation Consortium | Dr. Genevieve Giuliano | Sue Dexter |
| 29 | Metrolink (Southern California Regional Rail Authority) | Roderick Diaz | David Huang |
| 30 | National Resources Defense Council (NRDC) | Natalia Ospina | |
| 31 | Pacific Merchant Shipping Association (PMSA) | Michele Grubbs | Thomas Jelenic |
| 32 | Port of Long Beach (POLB) | Commissioner Sharon Weissman | Theresa Dau-Ngo |
| 33 | Port of Los Angeles (POLA) | Kerry Cartwright | Tony Gioiello |
| 34 | South Coast Air Quality Management District (AQMD) | | Dr. Sarah Rees/Dr. Aaron Katzenstein |
| 35 | Southeast Los Angeles (SELA) Collaborative | Dr. Wilma Franco | |
| 36 | Southern California Association of Governments (SCAG) | Scott Strelecki | Alison Linder |
| 37 | Union Pacific (UP) Railroad | Lupe Valdez | |
| 38 | USC Equity Research Institute (ERI) | Edward Muna | Dr. Manuel Pastor |

Metro

# នាទីលាច របៀបវារៈ #1៖ សេចក្តីព្រាងគោលការណ៍ដឹកនាំ សេចក្តីថ្លែងចក្ខុវិស័យ & គោលដៅ

Metro

# នាទីលាច របៀបវារៈ #1.1៖ ការសង្ខេបចំណុចសំខាន់នៃមតិចូលរួមដែលទទួលបាន

Metro

# សំណើខ្សែផ្លូវ I-710 ថ្មីភាគខាងត្បូង (5នាទី) – ចំណុចសំខាន់ៗ (អភិបាល Hahn, Solis, Mitchell និង Dutra)

## គោលនយោបាយ

> ការពង្រីកផ្លូវល្បឿនលឿនតាមរយៈការពង្រីកសមត្ថភាព ត្រូវបានផាត់ចេញពីគម្រោងនេះ

## លទ្ធភាពទទួលបាន

> ផ្តល់ជូនក្នុងខែមិថុនានូវសេចក្តីថ្លែងចក្ខុវិស័យ គោលការណ៍ដឹកនាំ និងគោលដៅរបស់ក្រុមការងារ
> រាយការណ៍ត្រឡប់មកវិញនៅក្នុងខែកញ្ញា ស្តីពីៈ

- ដាក់ឈ្មោះគម្រោងខ្សែផ្លូវ I-710 ភាគខាងត្បូងតាមរយៈកិច្ចដំណើរការរួមបញ្ចូលគ្នា
- គំនិតផ្តួចផ្តើមដំបូង (យ៉ាងតិចចំនួន 3)
- បច្ចុប្បន្នភាពព័ត៌មានស្តីពីការអភិវឌ្ឍគម្រោងវិនិយោគ

## ការចូលរួម

> សហការជាមួយភាគីពាក់ព័ន្ធដើម្បីគាំទ្រដល់គំនិតផ្តួចផ្តើម
> សហការជាមួយទីភ្នាក់ងារនិយ័តកម្មរបស់រដ្ឋនិងសហព័ន្ធដើម្បីទទួលបានការឯកភាព

Metro

# សេចក្តីថ្លែងការណ៍ចក្ខុវិស័យ និងការកំណត់ពេលវេលាអភិវឌ្ឍន៍គោលដៅ

រយៈពេលកំណត់នេះបង្ហាញពីសកម្មភាពសំខាន់ៗ និងកាលបរិច្ឆេទសម្រាប់ការបង្កើតសេចក្តីថ្លែងចក្ខុវិស័យ & គោលដៅរបស់ក្រុមការងារផ្លូវ 710 ។

## ខែកុម្ភ

**ថ្ងៃទី17 ខែកុម្ភៈ –** ណែនាំដំណាក់កាលរៀបចំចក្ខុវិស័យ & គោលដៅ នៅ ក្នុង កិច្ច ប្រជុំក្រុមការងារ # 5

**ថ្ងៃទី22 ខែកុម្ភៈ –** ចាប់ផ្តើមការស្ទង់មតិអំពីចក្ខុវិស័យ & គោលដៅ

**ថ្ងៃទី23 ខែកុម្ភៈ -** ពិភាក្សាអំពីការផ្សព្វផ្សាយការស្ទង់មតិ និងទម្រង់ សិក្ខាសាលានៅឯកិច្ចប្រជុំ ក្រុមការងារ យុទ្ធសាស្ត្រ ចូលរួម ជាមួយ សហគមន៍

## ខែមីនា

**ដើមខែមីនា -** ក្រុមការងារគម្រោងពិនិត្យលទ្ធផលស្ទង់មតិ បង្កើតសេចក្តីព្រាងបឋមអំពីសេចក្តីថ្លែងចក្ខុវិស័យ និងគោលដៅ

**ថ្ងៃទី14 ខែមីនា –** បង្ហាញលទ្ធផលស្ទង់មតិបឋម និងសេចក្តីព្រាង ដំបូងអំពីសេចក្តីថ្លែងចក្ខុវិស័យនិងគោលដៅ នៅ ក្នុងកិច្ចប្រជុំ ក្រុមការងារ #6

**ថ្ងៃទី23 ខែមីនា –** កិច្ចប្រជុំសាធារណៈស្តីពីការអភិវឌ្ឍគោលដៅ & ចក្ខុវិស័យ
ថ្ងៃទី30 ខែមីនា – បិទការស្ទង់មតិអំពីចក្ខុវិស័យនិងគោលដៅ

**ថ្ងៃទី31 ខែមីនា –** ពិភាក្សាចក្ខុវិស័យ & គោលដៅនៅឯកិច្ចប្រជុំចាប់ផ្តើមនៃ គណៈកម្មាធិការដឹកនាំសហគមន៍ (CLC)

## ខែមេសា

**ដើមខែមេសា –** ក្រុមការងារគម្រោងបញ្ចូលមតិចូលរួមទៅក្នុងសេចក្តីព្រាង ចុងក្រោយអំពីសេចក្តីថ្លែង ចក្ខុវិស័យ និងគោលដៅ

**ថ្ងៃទី5 ខែមេសា –** ពិភាក្សាអំពីចក្ខុវិស័យ & គោលដៅ ដែលបានមកពីទស្សនៈសមធម៌នៅឯកិច្ចប្រជុំចាប់ផ្តើមរបស់ក្រុមការងារសមធម៌

**ថ្ងៃទី11 ខែមេសា –** ការពិនិត្យមើលសេចក្តីព្រាងចក្ខុវិស័យនិងគោលដៅ នៅក្នុងកិច្ចប្រជុំក្រុមការងារ #7

**ថ្ងៃទី19 ខែមេសា–** ការពិនិត្យមើលមតិចូលរួមសាធារណៈស្តីពីចក្ខុវិស័យ & គោលដៅ នៅកិច្ចប្រជុំ CLC #2។

**ថ្ងៃទី19 ខែមេសា –** កិច្ចប្រជុំក្រុមការងារសមធម៌ #2 ណែនាំការកែលម្អទៅលើសេចក្តីព្រាងចក្ខុវិស័យនិងគោលដៅ ដែលបានមកពីទស្សនៈសមធម៌

**ថ្ងៃទី28 ខែមេសា –** កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល #1 - ការធ្វើបច្ចុប្បន្នភាព ដំណាក់កាល បង្កើត សេចក្តី ថ្លែង ចក្ខុវិស័យនិងគោលដៅ

## ខែឧសភា/ខែមិថុនា

:នទៃទនាដើយ

**ថ្ងៃទី9 ខែឧសភា –** កិច្ចប្រជុំក្រុមការងារ #8 កែលម្អសេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ & គោលដៅ

**ថ្ងៃទី13 ខែមិថុនា –** កិច្ចប្រជុំក្រុមការងារ #9
ពិចារណា និងបោះឆ្នោតលើសំណើសេចក្តីថ្លែងចក្ខុវិស័យ គោលការណ៍ដឹកនាំ & គោលដៅ

**ការបន្តចូលរួមរបស់សាធារណៈជន –** សមាជិកក្រុមការងារ និងសមាជិក សាធារណៈជនអាចដាក់ជូន មតិយោបល់ជាលាយលក្ខណ៍អក្សរ អ៊ីមែល ឬលិខិតទៅកាន់ Metro (ទីភ្នាក់ងារប្រព័ន្ធរថភ្លើងក្រោមដី) និង Caltrans (ក្រសួងដឹកជញ្ជូនរដ្ឋ California) ដើម្បីផ្តល់ជូននូវមតិចូលរួមលើការអភិវឌ្ឍ និងការអនុម័តសេចក្តីថ្លែងការណ៍ ចក្ខុវិស័យ & គោលដៅ សមាជិកសាធារណៈ ក៏អាចផ្តល់មតិយោបល់ជាសាធារណៈនៅអំឡុងកិច្ចប្រជុំក្រុមការងារ #5, 6, 7 និង 8 ។

Metro

# គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង

**ចក្ខុវិស័យ**

សេចក្តីថ្លែងសង្ខេបដែលរៀបរាប់អំពីមហិច្ឆតា បំណងប្រាថ្នា និងលទ្ធផលរួមនៃគម្រោង

**ចក្ខុវិស័យ:**

*សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ (ថ្ងៃទី11 ខែមេសា ឆ្នាំ2022)៖ ប្រព័ន្ធការដឹកជញ្ជូនប្រើប្រាស់រួមពហុមធ្យោបាយប្រកបដោយសមធម៌ ដែលគាំទ្រសហគមន៍ដែលមានខ្យល់អាកាសបរិសុទ្ធ សុខភាពល្អ និងប្រកបដោយនិរន្តរភាព ភាពជន់នៃសេដ្ឋកិច្ច និងការងារដែលមានគុណភាព ក៏ដូចជាផ្តល់ជូននូវជម្រើសចល័តភាពដែលមានសុវត្ថិភាពនិងគុណភាពដល់អ្នករស់នៅ និងអ្នកប្រើប្រាស់នៃតំបន់ខ្សែបន្ទាត់ផ្លូវលេខ I-710 ភាគខាងត្បូង។*

# គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង

**គោលដៅ**

លទ្ធផលដែលចង់បានសម្រាប់តំបន់ដែលមានក្តីបារម្ភ ដើម្បីគាំទ្រនិងសម្រេចបានចក្ខុវិស័យជារួម

**ចក្ខុវិស័យ** → **គោលដៅ៖**



**គុណភាពខ្យល់**
ពង្រឹងគុណភាពខ្យល់



**សហគមន៍**
កែលម្អសុខភាពនិងគុណភាពជីវិតរបស់អ្នករស់នៅនិងស្ថិរភាពរបស់សហគមន៍



**ចល័តភាព**
កែលម្អការបំលាស់ទីរបស់ប្រជាជននិងទំនិញ



**សុវត្ថិភាព**
ផ្តល់សហគមន៍ ផ្លូវថ្នល់ និងវិថីដែលមានសុវត្ថិភាព



**សេដ្ឋកិច្ច**
ផ្តល់ការងារដែលមានគុណភាព ការអភិវឌ្ឍកម្លាំងការងារ និងឱកាសសេដ្ឋកិច្ច



**និរន្តរភាព និងបរិស្ថាន**
ដោះស្រាយការប្រែប្រួលអាកាសធាតុ និងធ្វើឲ្យបរិស្ថានប្រសើរឡើង



**សមធម៌**
កាត់បន្ថយ ឬលុបបំបាត់ភាពខុសគ្នាក្នុងសហគមន៍នៅទូទាំងគ្រប់គោលដៅ

# សំណើសេចក្តីព្រាងគោលការណ៍ដឹកនាំ សេចក្តីថ្លែងចក្ខុវិស័យ និងគោលដៅ

ដើម្បីបំពេញដំណាក់កាលចក្ខុវិស័យនិងគោលដៅ ចាប់តាំងពីកិច្ចប្រជុំក្រុមការងារ #8 យើងបានអនុវត្តជំហានដូចខាងក្រោម៖

- ✓ បានជម្រុញការចូលរួមរបស់ក្រុមការងារគម្រោងផ្លូវ 710 ដែលបានចូលរួម គណៈកម្មាធិការដឹកនាំសហគមន៍ និងក្រុមការងារផ្សេងៗ
- ✓ បានរៀបចំកិច្ចប្រជុំពីរ និងម៉ោងធ្វើការងារសម្រាប់គណៈកម្មាធិការដឹកនាំសហគមន៍
- ✓ បានកែលម្អសំណើគោលការណ៍ដឹកនាំ សេចក្តីថ្លែងចក្ខុវិស័យ និងគោលដៅ ដើម្បីរួមបញ្ចូលនូវទស្សនៈយល់ឃើញផ្សេងៗគ្នាជាច្រើន

# នាទីលាច របៀបវារៈ #1.2៖ សមធម៌និងនិរន្តរភាពសម្រាប់ជាគោលការណ៍ដឹកនាំ

Metro

# គោលដៅដំបូងរបស់តំបន់ខ្សែបន្ទាត់ផ្លូវលេខ 710 ភាគខាងត្បូង




Metro

# ការបង្ហាញអំពីគោលការណ៍ដឹកនាំ

**គោលការណ៍ដឹកនាំ**

គុណតម្លៃដែលដឹកនាំរាល់ដំណើរការនិងលទ្ធផលទាំងអស់ តាមរយៈក្របខណ្ឌពាក់ព័ន្ធគ្នា និងដោយចេតនា

## បានដាក់ស្នើគោលវិធី



# ហេតុអ្វីត្រូវណែនាំបង្ហាញអំពីសមធម៌និងនិរន្តរភាពសម្រាប់ជាគោលការណ៍ដឹកនាំ?

សមធម៌ & និរន្តរភាពអនុវត្តចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៃផែនការវិនិយោគ និងក្រុមការងារតំបន់ខ្សែបន្ទាត់ផ្លូវលេខ 710 ភាគខាងត្បូង។

> គំរូពីមុន៖ ផែនការយុទ្ធសាស្ត្រចរាចរណ៍ទំនិញខោនធី LA (LA County Goods Movement Strategic Plan) ឆ្នាំ 2021

ជួយកំណត់និយមន័យសមធម៌និងនិរន្តរភាពបន្ថែមទៀត ដើម្បីសម្រេចបានការយល់ដឹងទូទៅ

> ឱកាសដើម្បីបញ្ជាក់ឱ្យច្បាស់នូវធាតុផ្សំពហុកម្រិតនៃសមធម៌និងយុត្តិធម៌ និងរបៀបដែលធាតុផ្សំទាំងនោះផ្សារភ្ជាប់ទៅនឹងដំណើរការរៀបចំផ្ទៃផែនការ៖ សមធម៌តាមបែបនីតិវិធី + មានលក្ខណៈចែកចាយ + ស្តារឡើងវិញ + ជារចនាសម្ព័ន្ធ

> ឱ្យនិយមន័យនៃនិរន្តរភាពដែលក្តោបអត្ថន័យទូលំទូលាយរបស់វា និងរបៀបដែលវាអនុវត្តចំពោះដំណើរការធ្វើផែនការ

> ឱ្យនិយមន័យនៃនិរន្តរភាពដែលក្តោបអត្ថន័យទូលំទូលាយរបស់វា និងរបៀបដែលវាអនុវត្តចំពោះដំណើរការធ្វើផែនការ

គោលការណ៍ដឹកនាំនឹង៖

> ជម្រាប ដំណឹង អំពី កិច្ច ដំណើរការនិងគំនិតផ្តួចផ្តើមនានានៅគ្រប់ដំណាក់កាលនៃគម្រោង

> ជួយដល់ ការពិភាក្សាគ្នា ជាក្រុម និងកំណត់អំពីចំណុចអាទិភាពនានា

> ផ្សារភ្ជាប់ធាតុផ្សំឯករាជ្យនានានៃការងារគម្រោង ទៅនឹងក្របខណ្ឌពាក់ព័ន្ធគ្នានិង ដោយ ចេតនា

> កាត់បន្ថយភាពច្រំ ដែលនៅក្នុងចំណោមវត្ថុបំណងនិងយុទ្ធសាស្ត្រ

# គោលការណ៍ដឹកនាំសមធម៌

**គោលការណ៍ដឹកនាំ**

គុណតម្លៃដែលដឹកនាំរាល់ដំណើរការនិងលទ្ធផលទាំងអស់ តាមរយៈក្របខណ្ឌពាក់ព័ន្ធគ្នា និងដោយចេតនា

ផែនការវិនិយោគខ្សែផ្លូវ I-710 ភាគខាងត្បូង មានមូលដ្ឋានគ្រឹះផ្អែកលើគោលការណ៍ដឹកនាំសមធម៌៖ “ការប្ដេជ្ញាចិត្ត៖ *(1) ខិតខំប្រឹងប្រែងកែប្រែបញ្ហាពីអតីតកាល (2) ផ្ដល់លទ្ធភាពទទួលបានឱកាសដោយត្រឹមត្រូវនិងយុត្តិធម៌ និង 3) លុបបំបាត់ភាពល្អៀងខុសគ្នានៅក្នុងដំណើរការនានារបស់គម្រោង ការសម្រេចបាន និងលទ្ធផលរបស់សហគមន៍។*

ផែនការនោះគឺធ្វើយ៉ាងណាបង្កើននិងបណ្ដុះគោលការណ៍សមធម៌នៅគ្រប់គោលដៅ វត្ថុបំណង យុទ្ធសាស្ត្រ និងវិធានការទាំងអស់ តាមរយៈក្របខណ្ឌសមធម៌តាមបែបនីតិវិធី មានលក្ខណៈចែកចាយ ជារចនាសម្ព័ន្ធ និងស្ដាឡើងវិញ និងតាមរយៈការផ្ដោតអាទិភាពទៅលើដំណើរការចូលរួមដែលអាចទទួលបាន និងមានលក្ខណៈជាតំណាង សម្រាប់សហគមន៍ដែលរងផលប៉ះពាល់បំផុតដោយគម្រោងផ្លូវ I-710។

Metro

# ការបង្ហាញអំពីគោលការណ៍ដឹកនាំនិរន្តរភាព

**គោលការណ៍ដឹកនាំ**

គុណតម្លៃដែលដឹកនាំរាល់ដំណើរការនិងលទ្ធផលទាំងអស់ តាមរយៈក្របខណ្ឌពាក់ព័ន្ធគ្នា និងដោយចេតនា

*ផែនការវិនិយោគតំបន់ខ្សែផ្លូវ I-710 ភាគខាងត្បូង គឺមានមូលដ្ឋានគ្រឹះផ្អែកលើគោលការណ៍ដឹកនាំនិរន្តរភាព៖ "ការអភិវឌ្ឍដែលបំពេញតាមតម្រូវការនាពេលបច្ចុប្បន្ន ដោយមិនធ្វើឱ្យប៉ះពាល់ដល់សមត្ថភាពរបស់មនុស្សជំនាន់ក្រោយក្នុងការបំពេញតាមតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ"។*

*"ការប្តេជ្ញាចិត្តទៅលើនិរន្តរភាពគឺជាការបំពេញបាននូវតម្រូវការសង្គម និងសេដ្ឋកិច្ចជាមូលដ្ឋាន ទាំងនាពេលបច្ចុប្បន្ននិងអនាគត និងការប្រើប្រាស់បរិស្ថានធម្មជាតិប្រកបដោយទំនួលខុសត្រូវ ដោយទាំងអស់នេះសុទ្ធតែរក្សាបាន ឬកែលម្អសុខុមាលភាពបរិស្ថានដែលជីវិតពឹងផ្អែកលើ។"*

Metro

# ការពិភាក្សារបស់ក្រុមការងារ

Metro

# ការសាកល្បងសម្រាប់មតិរួម –
# និរន្តភាពសម្រាប់ជាគោលការណ៍ដឹកនាំ

## តើអ្នកមានទស្សនៈយល់ឃើញដូចម្តេចទៅលើនិរន្តភាពសម្រាប់ជាគោលការណ៍ដឹកនាំ?



# មតិយោបល់សាធារណៈ

អ្នកនឹងមានពេល 1នាទី ដើម្បីសួរសំណួរឬផ្ដល់យោបល់ ដើម្បីបង្កើនការចូលរួមឲ្យបានច្រើន។



# ក្រុមការងារបោះឆ្នោតដើម្បីបញ្ជាក់អំពី “សមធម៌” និង “និរន្តរភាព” សម្រាប់ជាគោលការណ៍ដឹកនាំ

VOTE

ក្រុមការងារបោះឆ្នោតដើម្បីបញ្ជាក់អំពី “សមធម៌” និង “និរន្តរភាព” សម្រាប់ជាគោលការណ៍ដឹកនាំ

- ❑ បាទ/ចាស
- ❑ ទេ
- ❑ អនុប្បវាទ

Metro

# នាទីលាច របៀបវារៈ #1.3៖ សេចក្តីថ្លែងចក្ខុវិស័យ

Metro

# គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង

**ចក្ខុវិស័យ**

សេចក្តីថ្លែងសង្ខេបដែលរៀបរាប់អំពីមហិច្ឆតា បំណងប្រាថ្នា និងលទ្ធផលរួមនៃគម្រោង

**ចក្ខុវិស័យ:**

*សេចក្តីព្រាងនៃសេចក្តីថ្លែងចក្ខុវិស័យ (ថ្ងៃទី11 ខែមេសា ឆ្នាំ2022)៖ ប្រព័ន្ធការដឹកញ្ជូនប្រើប្រាស់រួមពហុមធ្យោបាយប្រកបដោយសមធម៌ ដែលគាំទ្រសហគមន៍ដែលមានខ្យល់អាកាសបរិសុទ្ធ សុខភាពល្អ និងប្រកបដោយនិរន្តរភាព ភាពធន់នៃសេដ្ឋកិច្ច និងការងារដែលមានគុណភាព ក៏ដូចជាផ្តល់ជូននូវជម្រើសចល័តភាពដែលមានសុវត្ថិភាពនិងគុណភាពដល់អ្នករស់នៅ និងអ្នកប្រើប្រាស់នៃតំបន់ខ្សែបន្ទាត់ផ្លូវលេខ I-710 ភាគខាងត្បូង។*

Metro

# សេចក្តីថ្លែងចក្ខុវិស័យ

**កិច្ចប្រជុំរបស់ក្រុមការងារអំពីសេចក្តីព្រាងសេចក្តីថ្លែងចក្ខុវិស័យនៃក្រុមការងារគម្រោង #7 (ថ្ងៃទី11 ខែមេសា ឆ្នាំ2022)** - ប្រព័ន្ធការដឹកជញ្ជូនប្រើប្រាស់រួមពហុមធ្យោបាយប្រកបដោយសមធម៌ ដែលគាំទ្រសហគមន៍ដែលមានខ្យល់អាកាសបរិសុទ្ធ សុខភាពល្អ និងប្រកបដោយនិរន្តរភាព ភាពធន់នៃសេដ្ឋកិច្ច និងការងារដែលមានគុណភាព ក៏ដូចជាផ្តល់ជូននូវជម្រើសចល័តភាពដែលមានសុវត្ថិភាពនិងគុណភាពដល់អ្នករស់នៅ និងអ្នកប្រើប្រាស់ផ្លូវលេខ I-710 ភាគខាងត្បូង។

**អនុសាសន៍ស្តីពីសេចក្តីថ្លែងចក្ខុវិស័យរបស់ក្រុមការងារសមធម៌ (ថ្ងៃទី19 ខែមេសា ឆ្នាំ2022)** - ប្រព័ន្ធការដឹកជញ្ជូនប្រើប្រាស់រួមពហុមធ្យោបាយប្រកបដោយសមធម៌ ដែលគាំទ្រសហគមន៍ដែលមានខ្យល់អាកាសបរិសុទ្ធ សុខភាពល្អ និងប្រកបដោយនិរន្តរភាព ភាពធន់នៃសេដ្ឋកិច្ច និងការងារដែលមានគុណភាព ក៏ដូចជាផ្តល់ជូននូវជម្រើសចល័តភាពដែលមានសុវត្ថិភាពនិងគុណភាពដល់អ្នករស់នៅ និងអ្នកប្រើប្រាស់ផ្លូវលេខ I-710 ភាគខាងត្បូង។

**អនុសាសន៍ស្តីពីសេចក្តីថ្លែងចក្ខុវិស័យរបស់គណៈកម្មាធិការដឹកនាំសហគមន៍ (ថ្ងៃទី23 ខែឧសភា ឆ្នាំ2022)** - ប្រព័ន្ធផ្លូវ I-710 ភាគខាងត្បូងប្រើប្រាស់រួមពហុមធ្យោបាយប្រកបដោយសមធម៌ ដែលអនុញ្ញាតឱ្យមានការលើកកម្ពស់ដល់សហគមន៍ដែលមានខ្យល់អាកាសបរិសុទ្ធ (គ្មានការបញ្ចេញផ្សែងពុល) មានសុខភាពល្អ និងប្រកបដោយនិរន្តភាព ការផ្តល់អំណាចសេដ្ឋកិច្ច និងផ្តល់នូវជម្រើសចល័តភាពដែលមានសុវត្ថិភាព និងប្រកបដោយសមធម៌សម្រាប់គ្រប់សហគមន៍ និងអ្នករស់នៅទាំងអស់។

**កិច្ចប្រជុំស្តីពីសេចក្តីថ្លែងចក្ខុវិស័យដែលបានស្នើឡើងដោយក្រុមការងារគម្រោងសម្រាប់ក្រុមការងារ #9 (ថ្ងៃទី13 ខែឧសភា ឆ្នាំ2022)** - ប្រព័ន្ធផ្លូវ I-710 ភាគខាងត្បូងប្រើប្រាស់រួមពហុមធ្យោបាយប្រកបដោយសមធម៌ ដែលអនុញ្ញាតឱ្យមានការលើកកម្ពស់ដល់សហគមន៍ដែលមានខ្យល់អាកាសបរិសុទ្ធ (គ្មានការបញ្ចេញផ្សែងពុល) មានសុខភាពល្អ និងប្រកបដោយនិរន្តភាព ការផ្តល់អំណាចសេដ្ឋកិច្ច និងផ្តល់នូវជម្រើសចល័តភាពដែលមានសុវត្ថិភាព និងប្រកបដោយសមធម៌សម្រាប់គ្រប់សហគមន៍ និងអ្នករស់នៅទាំងអស់នៅក្នុងបរិវេណផ្លូវដែកដឹកជញ្ជូនសំខាន់បំផុតរបស់ប្រទេស។

Metro

# សេចក្តីថ្លែងចក្ខុវិស័យ

**ចក្ខុវិស័យ**

សេចក្តីថ្លែងសង្ខេបដែលរៀបរាប់អំពីមហិច្ឆតា បំណងប្រាថ្នា និងលទ្ធផលរួមនៃគម្រោង

**ចក្ខុវិស័យ:**

**សេចក្តីថ្លែងចក្ខុវិស័យ (ថ្ងៃទី13 ខែឧសភា ឆ្នាំ2022)៖**

ប្រព័ន្ធផ្លូវ I-710 ភាគខាងត្បូងប្រើប្រាស់រួមពហុមធ្យោបាយប្រកបដោយសមធម៌ ដែលអនុញ្ញាតឱ្យមានការលើកកម្ពស់ដល់សហគមន៍ដែលមានខ្យល់អាកាសបរិសុទ្ធ (គ្មានការបញ្ចេញផ្សែងពុល) មានសុខភាពល្អ និងប្រកបដោយនិរន្តរភាព ការផ្តល់អំណាចសេដ្ឋកិច្ច និងផ្តល់នូវជម្រើសចល័តភាពដែលមានសុវត្ថិភាព និងប្រកបដោយសមធម៌សម្រាប់គ្រប់សហគមន៍ និងអ្នករស់នៅទាំងអស់នៅក្នុងបរិវេណផ្លូវដែកដឹកជញ្ជូនសំខាន់បំផុតរបស់ប្រទេស។

Metro

# ការពិភាក្សារបស់ក្រុមការងារ

Metro

# មតិរួមស្តីពីសំណើសេចក្តីព្រាងសេចក្តីថ្លែងចក្ខុវិស័យ

## តើអ្នកមានទស្សនៈយល់ឃើញដូចម្តេចទៅលើសំណើសេចក្តីព្រាងសេចក្តីថ្លែងចក្ខុវិស័យនេះ?




Metro

# មតិយោបល់សាធារណៈ

អ្នកនឹងមានពេល 1នាទី ដើម្បីសួរសំណួរឬផ្តល់យោបល់ ដើម្បីបង្កើនការចូលរួមឲ្យបានច្រើន។




Metro

# ការបោះឆ្នោតរបស់ក្រុមការងារទៅលើសំណើសេចក្តីថ្លែងចក្ខុវិស័យ

VOTE

## ខ្ញុំគាំទ្រដល់សំណើសេចក្តីថ្លែងចក្ខុវិស័យនេះ។

- ❑ បាទ/ចាស
- ❑ ទេ
- ❑ អនុប្បវាទ

Metro

# នាទីលាច របៀបវារៈ #1.4៖ គោលដៅ

Metro

# គោលវិធីចក្ខុវិស័យ គោលដៅ & វត្ថុបំណង

**គោលដៅ** លទ្ធផលដែលចង់បានសម្រាប់តំបន់ដែលមានក្តីបារម្ភ ដើម្បីគាំទ្រនិងសម្រេចបានចក្ខុវិស័យជារួម

**ចក្ខុវិស័យ** → **គោលដៅ៖**



**គុណភាពខ្យល់**
ពង្រឹងគុណភាពខ្យល់



**សហគមន៍**
កែលម្អសុខភាពនិងគុណភាពជីវិតរបស់អ្នករស់នៅនិងស្ថិរភាពរបស់សហគមន៍



**ចល័តភាព**
កែលម្អការបំលាស់ទីរបស់ប្រជាជននិងទំនិញ



**សុវត្ថិភាព**
ផ្តល់សហគមន៍ ផ្លូវថ្នល់ និងវិថីដែលមានសុវត្ថិភាព



**សេដ្ឋកិច្ច**
ផ្តល់ការងារដែលមានគុណភាព ការអភិវឌ្ឍកម្លាំងការងារ និងឱកាសសេដ្ឋកិច្ច



**និរន្តរភាព និងបរិស្ថាន**
ដោះស្រាយការប្រែប្រួលអាកាសធាតុ និងធ្វើឲ្យបរិស្ថានប្រសើរឡើង



**សមធម៌**
កាត់បន្ថយ ឬលុបបំបាត់ភាពខុសគ្នាក្នុងសហគមន៍នៅទូទាំងគ្រប់គោលដៅ

Metro

# Vision, Goals & Objectives Approach




Equity Working Group and Task Force feedback highlighted that Equity and Sustainability are broad and multilayered values that apply across all goals and objectives

Metro

# អនុសាសន៍របស់ CLC ស្តីពីគោលដៅគម្រោង

> សមាជិក CLC មួយចំនួនគិតថា គោលដៅមានភាពល្អប្រសើរនៅពេលគេគាក់តែងគោលដៅនោះឡើងនាពេលបច្ចុប្បន្ននេះ។ អ្នកខ្លះទៀតគិតថា មូលបទនៃមតិយោបល់របស់ CLC បានរួមបញ្ចូលនូវ៖

- សមាជិក CLC មួយចំនួនគិតថា គោលដៅនេះគួរតែមានភាពជាក់លាក់ (ឧ.ទា. ពាក្យ “កែលម្អ” គឺមានន័យមិនច្បាស់ខ្លាំង ហើយអនុញ្ញាតឱ្យមានការកែប្រែតិចតួច/តាមលំដាប់ដើម្បីបំពេញតាមគោលដៅនេះ)។
- គោលដៅ “សហគមន៍” គួរតែសរសេរឃ្លាប្រយោគឡើងវិញ។ មិនច្បាស់ថាតើ “ស្ថេរភាពសហគមន៍” មានន័យដូចម្តេច។
- គោលដៅ “និរន្តរភាព/បរិស្ថាន” គួរតែរួមបញ្ចូលសេចក្តីយោងទៅលើ “សោភ័ណភាព”។
- “ការកាត់បន្ថយសំឡេងរំខាន” គួរតែរួមបញ្ចូលនៅក្នុងគោលដៅមួយ។

# មតិចូលរួមរបស់ក្រុមការងារស្តីពីគោលដៅគម្រោង

សមាជិកក្រុមការងារមួយចំនួនគិតថា គោលដៅមានភាពល្អប្រសើរនៅពេលគេតាក់តែងគោលដៅនោះឡើងនាពេលបច្ចុប្បន្ននេះ។   អ្នកខ្លះទៀតគិតថា មតិយោបល់ស្តីពីសេចក្តីព្រាងគោលដៅបានរួមបញ្ចូលនូវ៖

- ភាពចាំបាច់ការក្នុងការផ្តោតលើការកែលម្អគុណភាពខ្យល់អាកាសតាមមូលដ្ឋាន
- បម្លាស់ទីទំនិញ ចាំបាច់ត្រូវលើកមកបញ្ជាក់ឱ្យបានច្បាស់
- សុវត្ថិភាពសម្រាប់ "ផ្លូវនិងថ្នល់" គឺផ្តោតតែទៅលើថយន្តខ្លាំងពេក
- សុវត្ថិភាពគួរតែរួមបញ្ចូលសុវត្ថិភាពបុគ្គល
- ពាក្យស្មេរភាពសហគមន៍ មានន័យមិនច្បាស់
- មិនច្បាស់អំពីការងារនិងឱកាសសម្រាប់នរណាម្នាក់
- មិនច្បាស់ថាតើជាការផ្តល់ការងារដែលមានគុណភាពឬយ៉ាងណា
- គួរតែយោងទៅលើមជ្ឈដ្ឋានទាំងធម្មជាតិនិងកែច្នៃ

Metro

# សំណើគោលដៅ

## គុណភាពខ្យល់

សេចក្តីព្រាងគោលដៅដែលបានកែប្រែ៖ **លើកកម្ពស់គុណភាពខ្យល់អាកាសស្អាតបរិសុទ្ធតាមមូលដ្ឋាននិងក្នុងតំបន់**

*សេចក្តីព្រាងគោលដៅអាទិភាព៖ កែលម្អគុណភាពខ្យល់*

## ចល័តភាព

សេចក្តីព្រាងគោលដៅដែលបានកែប្រែ៖ **កែលម្អការបំលាស់ទីរបស់ប្រជាជននិងទំនិញ**

*សេចក្តីព្រាងគោលដៅអាទិភាព៖ កែលម្អការបំលាស់ទីរបស់ប្រជាជននិងទំនិញ*

## សហគមន៍

សេចក្តីព្រាងគោលដៅដែលបានកែប្រែ៖ **គាំទ្រដល់សហគមន៍ដែលមាននិរន្តរភាពដោយការលើកកម្ពស់សុខភាព និងគុណភាបជីវិតរស់នៅរបស់ប្រជាជន**

*សេចក្តីព្រាងគោលដៅអាទិភាព៖ កែលម្អសុខភាពនិងគុណភាពជីវិតរបស់អ្នករស់នៅ និងស្ថិរភាពរបស់សហគមន៍*

## សុវត្ថិភាព

សេចក្តីព្រាងគោលដៅដែលបានកែប្រែ៖ **អនុញ្ញាតឱ្យមធ្យោបាយធ្វើដំណើរទាំងអស់កាន់តែមានសុវត្ថិភាព**

*សេចក្តីព្រាងគោលដៅអាទិភាព៖ ផ្តល់ជូននូវផ្លូវថ្នល់ វិថី និងសហគមន៍ដែលមានសុវត្ថិភាព*

## សេដ្ឋកិច្ច

សេចក្តីព្រាងគោលដៅដែលបានកែប្រែ៖ **ជំរុញលទ្ធភាពទទួលបានការងារដែលមានគុណភាព ការអភិវឌ្ឍកម្លាំងពលកម្ម និងឱកាសសេដ្ឋកិច្ច**

*សេចក្តីព្រាងគោលដៅអាទិភាព៖ ផ្តល់ការងារដែលមានគុណភាព ការអភិវឌ្ឍកម្លាំងការងារ និងឱកាសសេដ្ឋកិច្ច*

## បរិស្ថាន

សេចក្តីព្រាងគោលដៅដែលបានកែប្រែ៖ **លើកកម្ពស់បរិស្ថានធម្មជាតិនិងកែច្នៃ**

*សេចក្តីព្រាងគោលដៅអាទិភាព៖ ដោះស្រាយការប្រែប្រួលអាកាសធាតុ និងធ្វើឱ្យបរិស្ថានប្រសើរឡើង*

Metro

# ការពិភាក្សារបស់ក្រុមការងារ

Metro

# ការសាកល្បងសម្រាប់មតិរួមស្តីពីសំណើគោលដៅ

## តើអ្នកមានទស្សនៈយល់ឃើញដូចម្តេចទៅលើសំណើគោលដៅនេះ?



# មតិយោបល់សាធារណៈ

អ្នកនឹងមានពេល 1នាទី ដើម្បីសួរសំណួរឬផ្តល់យោបល់ ដើម្បីបង្កើនការចូលរួមឲ្យបានច្រើន។



# ក្រុមការងារត្រូវបោះឆ្នោតលើសំណើគោលដៅនេះ

VOTE

## ខ្ញុំគាំទ្រដល់សំណើគោលដៅនេះ។

- ☐ បាទ/ចាស
- ☐ ទេ
- ☐ អនុប្បវាទ

# នាទីលាច របៀបវារៈ #2៖ បច្ចុប្បន្នភាពក្រុមការងារគម្រោង

Metro

# នាទីលាច របៀបវារៈ #2.1៖ បច្ចុប្បន្នភាពលើជម្រើសគ្មានការសាងសង់/សំណើខ្សែផ្លូវ I-710 ភាគខាងត្បូងថ្មី

Metro

# បច្ចុប្បន្នភាពលើជម្រើសគ្មានការសាងសង់/ សំណើខ្សែផ្លូវ I-710 ភាគខាងត្បូងថ្មី

នៅក្នុងកិច្ចប្រជាក្រុមប្រឹក្សាភិបាលនៅថ្ងៃទី26 ខែឧសភារបស់ខ្លួន ប្រធានក្រុមប្រឹក្សាភិបាល Metro បានឯកភាពទៅលើ "សំណើខ្សែផ្លូវ I-710 ភាគខាងត្បូង" ដោយអភិបាល Hahn, Solis, Mitchell, និង Dutra ដែលស្នើរកចំណុចខាងក្រោម៖

- រាយការណ៍ត្រឡប់វិញនៅខែមិថុនា ឆ្នាំ2022 ស្តីពីគោលការណ៍ដឹកនាំ សេចក្តីថ្លែងចក្ខុវិស័យ និងគោលដៅដែលបានផ្តល់អនុសាសន៍របស់ក្រុមការងារ សម្រាប់ការពិចារណានិងការឯកភាពរបស់ក្រុមប្រឹក្សាភិបាល
- ការដាក់ឈ្មោះឡើងវិញលើគម្រោងខ្សែផ្លូវ I-710 ភាគខាងត្បូងមកត្រឹមខែកញ្ញា ឆ្នាំ2022 ដោយមានការពិគ្រោះយោបល់ជាមួយក្រុមការងារគម្រោង 710 និងភាគីពាក់ព័ន្ធនឹងខ្សែផ្លូវនេះ ដើម្បីរួមបញ្ចូលកាន់តែច្រើននូវអាទិភាពនិងអភិក្រមនានាដែលនឹងត្រូវបានជំរុញឱ្យអនាគតនៃគម្រោងនេះមានភាពជឿនលឿនទៅមុខ ដោយផ្តល់ការយកចិត្តទុកដាក់ឱ្យបានកាន់តែច្រើនលើសពីផ្លូវល្បឿនលឿននេះទៀត។
- ដោយសារតែការពង្រីកផ្លូវល្បឿនលឿនតាមរយៈការពង្រីកសមត្ថភាពនឹងទទួលបានការគាំទ្រពី Caltrans ឬ U.S. EPA ដូច្នេះយើងក៏អនុម័តជាគោលការណ៍របស់ក្រុមប្រឹក្សាភិបាលថា ការពង្រីកផ្លូវល្បឿនលឿនតាមរយៈការពង្រីកសមត្ថភាព នឹងលែងមាននៅក្នុងគម្រោងនេះទៀតហើយ

Metro

# សំណើខ្សែផ្លូវ I-710 ភាគខាងត្បូងថ្មី

A. អភិវឌ្ឍនិងអនុវត្តផែនការអភិវឌ្ឍគម្រោងដោយ៖
   1. រួមបញ្ចូលមតិកែលម្អពីក្រុមការងារគម្រោង 710 និងក្រុមការងារនិងគណៈកម្មាធិការដឹកនាំសហគមន៍របស់ខ្លួន ទីក្រុងខ្សែផ្លូវ ក្រុមប្រឹក្សារដ្ឋាភិបាលនៃទីក្រុងតំបន់ហ្គេតវេយ៍ (Gateway Cities Council of Governments) និងភាគីពាក់ព័ន្ធក្នុងសហគមន៍។
   2. ធ្វើឱ្យគំនិតផ្តួចផ្តើមមានភាពស្របគ្នានឹងឱកាសមូលនិធិ រួមមាន៖
      a. ផែនការវិនិយោគដើមដំបូងសម្រាប់គំនិតផ្តួចផ្តើមអប្បរមាចំនួនបីដែលនឹងដាក់ពាក្យសុំទទួលបានឱកាសមូលនិធិរដ្ឋនិងសហព័ន្ធដែលមានផ្តល់ជូននៅក្នុងប្រតិទិនឆ្នាំ2022 និង
      b. ផែនការវិនិយោគរយៈពេលមធ្យម និងរយៈពេលវែងសម្រាប់គំនិតផ្តួចផ្តើមដែលអាចមានលទ្ធភាពសមស្របក្នុងការដាក់ពាក្យសុំទទួលបានឱកាសមូលនិធិរដ្ឋនិងសហព័ន្ធនៅក្នុងឆ្នាំខាងមុខៗទៀត។
   3. ប្រើប្រាស់មូលនិធិក្នុងវិធានការ R និងវិធានការ M ដែលអាចអនុវត្តបានដើម្បីបង្កើនជាអតិបរមានៃលទ្ធផលទទួលបាន និងភាពស៊ីគ្នានៃមូលនិធិរដ្ឋនិងសហព័ន្ធ។
   4. ផ្តល់ជូននូវបណ្តុំនៃការវិនិយោគដ៏ធំដែលអាចនឹងត្រូវបញ្ចប់មិនហួសពីឆ្នាំ2028។
   5. កំណត់ឱកាសមូលនិធិសហព័ន្ធដែលអាចនឹងត្រូវបានរួមបញ្ចូលទៅក្នុងសកម្មភាពវិនិយោគហេដ្ឋារចនាសម្ព័ន្ធនិងការងារ "យុទ្ធសាស្ត្រមូលនិធិជំនួយ និងផែនការអភិវឌ្ឍរយៈពេល 5ឆ្នាំ" ដែលស្ថិតក្រោមការអភិវឌ្ឍនាពេលបច្ចុប្បន្នសម្រាប់ការធ្វើបទបង្ហាញទៅដល់ក្រុមប្រឹក្សាភិបាល Metro។

Metro

# សំណើខ្សែផ្លូវ I-710 ភាគខាងត្បូងថ្មី

B. ជំរុញការចូលរួមរបស់ក្រសួងដឹកជញ្ជូនរដ្ឋកាលីហ្វ័រញ៉ា (California Department of Transportation) និងទីភ្នាក់ងារដឹកជញ្ជូនរដ្ឋ ក្រុមប្រឹក្សាសង្គ្រោះខ្យល់អាកាសរដ្ឋកាលីហ្វ័រញ៉ា (California Air Resources Board) គណៈកម្មាធិការផ្នែកថាមពលនៃរដ្ឋកាលីហ្វ័រញ៉ា (California Energy Commission) និងក្រសួងថាមពលនិងដឹកជញ្ជូនរបស់សហរដ្ឋអាមេរិក (U.S. Departments of Energy and Transportation) ព្រមទាំងទីភ្នាក់ងារការពារបរិស្ថានសហរដ្ឋអាមេរិក (U.S. Environmental Protection Agency) ដើម្បីបង្កើតការណែនាំស្តីពីផែនការវិនិយោគរយៈពេលមធ្យមនិងរយៈពេលវែង។

C. ជំរុញការចូលរួមរបស់ទីក្រុង ខោនធី និងដៃគូក្នុងតំបន់ រួមទាំងមណ្ឌលគ្រប់គ្រងគុណភាពតំបន់ឆ្នេរភាគខាងត្បូង(South Coast Air Quality Management District) និងក្រុមហ៊ុនបច្ចេកវិទ្យា Los Angeles Cleantech Incubator ដើម្បីរៀបចំ និងគាំទ្រដល់គំនិតផ្តួចផ្តើមតាមមូលដ្ឋានសម្រាប់ជាផ្នែកមួយនៃផែនការវិនិយោគរបស់គម្រោង និង

D. រាយការណ៍ត្រឡប់មកវិញនៅខែកញ្ញា ឆ្នាំ2022 ស្តីពីការអភិវឌ្ឍនិងការអនុវត្តនៃយុទ្ធសាស្ត្រវិនិយោគនេះ រួមទាំងគំនិតផ្តួចផ្តើមអតិបរមាចំនួនបីដែលអនុវត្តទៅលើមូលនិធិរដ្ឋនិងសហព័ន្ធដែលមានផ្តល់ជូននៅក្នុងប្រតិទិនឆ្នាំ2022។

# ចំណុចគោលជំហានទីIII/IV៖ គំនិតផ្តួចផ្តើមដំបូងឆ្នាំ2022

នៅកិច្ចប្រជុំក្រុមប្រឹក្សាថ្ងៃទី26 ខែឧសភា ឆ្នាំ2022 របស់ខ្លួន ក្រុមប្រឹក្សាភិបាលរបស់ Metro បានអនុម័តលើសំណើមួយដែលបានបន្ថែមកិច្ចការនិងលក្ខខណ្ឌបន្ថែមសម្រាប់ការបញ្ចប់ផែនការវិនិយោគសម្រាប់ផ្លូវ I-710 ភាគខាងត្បូង។

ក្នុងចំណោមលក្ខខណ្ឌទាំងនេះ គឺមានលក្ខខណ្ឌតម្រូវដើម្បីកំណត់និយមន័យ៖

*ផែនការវិនិយោគដើមដំបូងសម្រាប់គំនិតផ្តួចផ្តើមអប្បរមាចំនួនបីដែលនឹងដាក់ពាក្យសុំទទួលបានឱកាសមូលនិធិរដ្ឋនិងសហព័ន្ធដែលមានផ្តល់ជូននៅក្នុងប្រតិទិនឆ្នាំ2022។*

យើងកំពុងតែហៅលក្ខខណ្ឌតម្រូវទាំងនេះថាជា “គំនិតផ្តួចផ្តើមដំបូង” ដែលត្រូវតែបានកំណត់និយមន័យនៅក្នុងរបាយការណ៍ត្រឡប់ទៅវិញទៅកាន់ក្រុមប្រឹក្សាភិបាល Metro នៅក្នុងខែកញ្ញា ឆ្នាំ2022។ ជំហានបន្ថែមទាំងនេះនឹងប្រព្រឹត្តទៅស្របគ្នាជាមួយនឹងសកម្មភាពផ្សេងទៀតនៃក្រុមការងារ និងគណៈកម្មាធិការដឹកនាំសហគមន៍។

ប្រគល់ព័ត៌មានស្តីពីគម្រោងគំនិតផ្តួចផ្តើមដំបូងនៅត្រឹមថ្ងៃ**សុក្រ ទី1 ខែកក្កដា**

Metro

# ការពិភាក្សារបស់ក្រុមការងារ

Metro

# មតិយោបល់សាធារណៈ

អ្នកនឹងមានពេល 1នាទី ដើម្បីសួរសំណួរឬផ្តល់យោបល់ ដើម្បីបង្កើនការចូលរួមឲ្យបានច្រើន។




Metro

# នាទីល្ងាច របៀបវារៈ #3៖ ការរាយការណ៍លម្អិត៖

Metro

# នាទីលាច របៀបវារៈ #3.1៖ ការបញ្ជាក់អំពីសមាជិក CLC ថ្មី

Metro

# ការបញ្ជាក់របស់ក្រុមការងារអំពីសមាជិកគណៈកម្មាធិការដឹកនាំសហគមន៍ថ្មី

**សំណើ៖**

**ក្រុមការងារដែលត្រូវពិចារណាលើការតែងតាំង Jamila Cervantes (Maywood) ជាសមាជិកគណៈកម្មាធិការដឹកនាំសហគមន៍ (CLC) ថ្មី។**

Metro

# សំណើរបស់ក្រុមការងារ

Metro

# ការបោះឆ្នោតរបស់ក្រុមការងារដើម្បីបញ្ជាក់ទទួលសមាជិកគណៈកម្មាធិការដឹកនាំសហគមន៍ (CLC)

VOTE

**ខ្ញុំគាំទ្រការតែងតាំងសមាជិកគណៈកម្មាធិការដឹកនាំសហគមន៍ (CLC) ថ្មី។**

- ❑ បាទ/ចាស
- ❑ ទេ
- ❑ អនុប្បវាទ

Metro

# កិច្ចប្រជុំនិងការតម្រង់ទិសរបស់គណៈកម្មាធិការដឹកនាំសហគមន៍ #3

## សេចក្តីសង្ខេបអំពីការតម្រង់ទិស

- បានរៀបចំឡើងតាមរយៈកម្មវិធី Zoom អនឡាញនៅថ្ងៃពុធ ទី11 ខែឧសភា
- សមាជិក CLC ចំនួន 16 រូបកំពុងចូលរួម

## សេចក្តីសង្ខេបអំពីកិច្ចប្រជុំ #2

- បានរៀបចំឡើងតាមរយៈកម្មវិធី Zoom អនឡាញនៅថ្ងៃព្រហស្បតិ៍ ទី19 ខែឧសភា និងថ្ងៃទី23 ខែឧសភា
- សមាជិក CLC ចំនួន 15 រូបកំពុងចូលរួម (5/19) &សមាជិក CLC 17 រូបកំពុងចូលរួម (5/23)

## ការរំលេចផ្នែកសំខាន់ៗ

  - បានបោះឆ្នោតទៅលើសេចក្តីថ្លែងចក្ខុវិស័យរបស់ CLC
  - បានពិនិត្យឡើងវិញ និងបានផ្តល់មតិយោបល់ស្តីពីគោលដៅ

## ការគិតពីអនាគតនៃកិច្ចប្រជុំ

- កាលបរិច្ឆេទ៖  ថ្ងៃព្រហស្បតិ៍ ទី23 ខែមិថុនា ម៉ោង 5-7 យប់

Metro

# សង្ខេបចំណុចសំខាន់នៃកិច្ចប្រជុំក្រុមការងារ #8

**សេចក្តីសង្ខេប**

- បានរៀបចំឡើងតាមរយៈកម្មវិធី Zoom អនឡាញនៅថ្ងៃចន្ទ ទី11 ខែមេសា ឆ្នាំ2022
- អ្នកចូលរួមចំនួន 103នាក់ (សមាជិកក្រុមការងារ/អ្នកជំនួសចំនួន 33នាក់ សមាជិកគណៈកម្មាធិការ CLC ចំនួន 3 នាក់ និងសមាជិកសាធារណៈចំនួន 67នាក់)

**ការរំលេចផ្នែកសំខាន់ៗ**

- ✓ បានបញ្ជាក់ទទួលសមាជិកថ្មីនៃគណៈកម្មាធិការដឹកនាំសហគមន៍ (CLC)
- ✓ បានពិភាក្សាអំពីមតិកែលម្អទៅលើចក្ខុវិស័យ គោលដៅ & វត្ថុបំណង
- ✓ បានបោះឆ្នោត “សមធម៌” សម្រាប់ជាគោលការណ៍ដឹកនាំ
- ✓ បានធ្វើបទបង្ហាញអំពីសំណើសុំណែនាំអំពី “និរន្តរភាព” ជាគោលការណ៍ដឹកនាំ
- ✓ បានពិនិត្យនិងពិភាក្សាអំពីសេចក្តីព្រាងសេចក្តីថ្លែងចក្ខុវិស័យនិងគោលដៅ
- ✓ បានចូលរួមក្នុងការបង្កើតមតិរួម ដើម្បីកែលម្អសេចក្តីព្រាងសេចក្តីថ្លែងចក្ខុវិស័យនិងគោលដៅ

Metro

# សង្ខេបចំណុចសំខាន់នៃកិច្ចប្រជុំរបស់ក្រុមការងាររថយន្តដឹកទំនិញដែលមិនបញ្ចេញផ្សែងពុល #6

## សេចក្តីសង្ខេប

> បានរៀបចំឡើងតាមប្រព័ន្ធ Zoom អនឡាញនៅថ្ងៃអង្គារ ទី19 ខែមេសា

> អ្នកចូលរួមចំនួន 51នាក់ (សមាជិកក្រុមការងារ/អ្នកជំនួសចំនួន 17នាក់ សមាជិកគណៈកម្មាធិការ CLC ចំនួន 3 នាក់ និងសមាជិកក្រុមការងារចំនួន 10នាក់)

## ការរំលេចផ្នែកសំខាន់ៗ

✓ ការពិភាក្សាក្នុងបន្ទប់បំបែកតាមក្រុមស្តីពីការគាំទ្រកម្មវិធីរថយន្តគ្មានការបញ្ចេញផ្សែងពុល (ZE) នៅលើប្រធានបទខាងក្រោម៖

- ការចូលរួមរបស់សហគមន៍ អត្ថប្រយោជន៍សហគមន៍ ការពិចារណាលើសមធម៌ ទីតាំងហេដ្ឋារចនាសម្ព័ន្ធមិនបញ្ចេញផ្សែងពុល លទ្ធផលកម្មវិធី
- ភាពជាដៃគូយុទ្ធសាស្ត្រ និងឱកាសមូលនិធិ
- គំនិតផ្តួចផ្តើមផ្នែកច្បាប់ និងគោលនយោបាយ
- ទឹកប្រាក់បម្រុងទុកតិចតួចសម្រាប់ការឧបត្ថម្ភធនយានយន្ត
- ផលប៉ះពាល់ផ្នែកបរិស្ថាន យុទ្ធសាស្ត្រកាត់បន្ថយផលប៉ះពាល់ និងលទ្ធផលនៃកម្មវិធី

Metro

# ការសង្ខេបចំណុចសំខាន់នៃកិច្ចប្រជុំរបស់ក្រុមការងារសមធម៌ #3

## សេចក្តីសង្ខេប

> បានរៀបចំឡើងតាមតាមរយៈកម្មវិធី Zoom តាមអនឡាញ នៅថ្ងៃពុធ ទី18 ខែឧសភា

> អ្នកចូលរួមចំនួន 12នាក់ (សមាជិកក្រុមការងារចំនួន 6នាក់ សមាជិក CLC ចំនួន 5នាក់ និងសមាជិក GCCOG ចំនួន 1នាក់)

> វត្ថុបំណងនៃកិច្ចប្រជុំរួមមានៈ
- ការពិនិត្យឡើងវិញលើគោលបំណងនៃការរៀបចំផែនការសមធម៌ និងឧបករណ៍វាយតម្លៃ (EPET) ពាក្យគន្លឹះ និងវឌ្ឍនភាពមកដល់ពេលនេះ
- ពិភាក្សាអំពីបរិបទសមធម៌ជាប្រវត្តិសាស្ត្រនៃខ្សែផ្លូវ I-710 ភាគខាងត្បូង និងសហគមន៍នៅជុំវិញ។
- ពិភាក្សាថាតើអភិក្រមសមធម៌តាមនីតិវិធីអាចដឹកនាំកិច្ចដំណើរការផ្សព្វផ្សាយជាបន្តរបស់គម្រោងបានយ៉ាងដូចម្តេច

## ការរំលេចផ្នែកសំខាន់ៗ

- សារៈសំខាន់នៃការរួមបញ្ចូល EPET ទៅក្នុងគ្រប់កិច្ចដំណើរការក្រុមការងារផ្សេងៗទាំងអស់ ជាពិសេសក្នុងករណីដែលសមធម៌ត្រូវបានរួមបញ្ចូលជាគោលការណ៍ដឹកនាំ។
- សារៈសំខាន់នៃការទទួលបានសមធម៌ដែលមានលក្ខណៈស្តារឡើងវិញសម្រាប់ទាំងអ្នកដែលស្ថិតក្នុងខ្សែផ្លូវនេះ និងអ្នកដែលបានផ្លាស់ទីលំនៅចេញរួចហើយពីខ្សែផ្លូវនេះដោយសារតែការសាងសង់ផ្លូវល្បឿនលឿន និងគ្រោះថ្នាក់ផ្សេងៗពីមុនមក។
- សារៈសំខាន់នៃការនាំយកព័ត៌មានគម្រោងទៅក្នុងព្រឹត្តិការណ៍ ឬទីកន្លែងដែលមានស្រាប់ពាក់ព័ន្ធនឹងស្ថាប័ននៅតាមសហគមន៍ សាលារៀន ស្ថាប័នផ្អែកតាមជំនឿនិងវប្បធម៌ ជាពិសេសអ្នកដែលពាក់ព័ន្ធនឹងក្រុមដែលពុំត្រូវបានគេយកចិត្តទុកដាក់ និង/ឬក្រុមដែលរងផលប៉ះពាល់ខ្លស់។

## ជំហានបន្ទាប់

> ពិនិត្យឡើងវិញលើការវិភាគនិងការកំណត់ផែនទីទិន្នន័យពាក់ព័ន្ធនឹងសមធម៌

> ពិភាក្សាអំពីតួនាទី EWG នៅក្នុងដំណាក់កាលនៃយុទ្ធសាស្ត្រមធ្យោបាយចម្រុះ និងគម្រោង

Metro

# ការសង្ខេបចំណុចសំខាន់នៃកិច្ចប្រជុំរបស់ក្រុមការងារសមធម៌ #3

## បរិបទសមធម៌ជាប្រវត្តិសាស្ត្រ

- បទបង្ហាញនិងការពិភាក្សាដែលផ្ដោតលើការដោះស្រាយសំណួរ EPET៖ *"តើការវិនិយោគ ការសម្រេចចិត្ត ព្រឹត្តិការណ៍ ឬការអភិវឌ្ឍជាប្រវត្តិសាស្ត្រអ្វីខ្លះដែលបានរួមចំណែកដល់ស្ថានភាពសហគមន៍នាពេលបច្ចុប្បន្ន?"*
- កំណើនលំនៅដ្ឋាននិងឧស្សាហកម្មនៅដើមដំបូង
- ការបដិសេធមិនផ្ដល់កម្ចី គោលនយោបាយ និងការផ្លាស់ប្ដូរប្រជាជន
- ការសាងសង់ផ្លូវល្បឿនលឿន និងការផ្លាស់ទីលំនៅ
- វិសមភាពការដឹកជញ្ជូនក្នុងតំបន់ ភាពរាំងស្ទះ និងវឌ្ឍនភាព
- ការផ្លាស់ប្ដូរប្រជាសាស្ត្រពីពេលមួយទៅពេលមួយ



អ្នកជំនួញស្រ្តីជនជាតិស្បែកសបានផ្សព្វផ្សាយអំពី "ដែនដីហ៊ុំព័ទ្ធដោយជនជាតិអង់គ្លេសសុទ្ធសាធ" នៅក្នុងរដ្ឋ LA ភាគខាងត្បូង
(ប្រភព៖ ឯកសាររូបថតទីក្រុង, KCET)


មណ្ឌលឧស្សាហកម្មកណ្ដាលដែលមានកំពុងសាងសង់ផ្លូវ I-710 នៅផ្នែកខាងមុខ ឆ្នាំ1956 (ប្រភព៖ បណ្ដុំរូបភាពនិងរូបថតរបស់ Kelly-Holiday, បណ្ណាល័យសាធារណៈរដ្ឋ Los Angeles)

## អភិក្រមសមធម៌តាមបែបនីតិវិធី

- តើយើងចាំបាច់ត្រូវភ្ជាប់ទំនាក់ទំនងជាមួយ**នរណា**?
- តើទំនាក់ទំនង**ប្រភេទណា**ដែលមានប្រសិទ្ធភាពបំផុត?
- តើយើងគួរមានការសន្ទនាទាំងអស់នេះនៅ**កន្លែងណា**?
- តើ**ពេលណា**ជាពេលវេលាសមស្របក្នុងការចូលរួមឱ្យមានប្រសិទ្ធភាពបំផុត?
- តើត្រូវទំនាក់ទំនងប្រាប់**ដូចម្ដេចថាហេតុអ្វី**បានជាវាសំខាន់ក្នុងការចូលរួម?

"ការឃោសនាតាមបញ្ជរ & ដោយផ្ទាល់នៅក្នុងព្រឹត្តិការណ៍សហគមន៍ដោយប្រើឯកសារមួយទំព័រ។"

"ក្រុមផ្អែកតាមជំនឿ វិទ្យាល័យ ស្ថាប័នយុវជន"

"ស្ថាប័នអាជីវកម្ម សហជីពកម្មករ អ្នកផ្ដល់សេវាលំនៅដ្ឋាន"

"ក្លឹបជិះកង់តាមមូលដ្ឋាន ក្លឹបជិះឡាន ក្រុមដើរ អ្នកជិះឡានក្រុង"

"គ្លីនិកដែលមានឯកទេសជំនាញខាងជំងឺហឺត"

Metro

# សង្ខេបចំណុចសំខាន់នៃកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល #2

## សេចក្តីសង្ខេប

> កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួល #2 ដែលបានរៀបចំឡើងតាមកម្មវិធី Zoom នៅថ្ងៃអង្គារ ទី25 ខែមិថុនា ឆ្នាំ2022

> មានវត្តមានសមាជិកគណៈកម្មាធិការសម្របសម្រួលចំនួន 5នាក់

## ការរំលេចផ្នែកសំខាន់ៗ

- ✓ សំណើរបស់ក្រុមប្រឹក្សាភិបាល Metro និងផលប៉ះពាល់ទៅលើកិច្ចការក្រុមការងារខ្សែផ្លូវ 710
- ✓ ការកំណត់ពីគម្រោង/កម្មវិធីក្នុងពេលដ៏ខ្លីខាងមុខ
- ✓ មូលនិធិជំនួយឆ្នាំ2022
- ✓ ការពិនិត្យឡើងវិញលើរបៀបវារៈសម្រាប់ CLC និងក្រុមការងារផ្សេងៗ

Metro

# មតិយោបល់សាធារណៈទូទៅ និងសុន្ទរកថាបិទបញ្ចប់

Metro

# មតិយោបល់សាធារណៈ

អ្នកនឹងមានពេល 2នាទីដើម្បីសួរសំណួរឬផ្តល់យោបល់ ដើម្បីបង្កើនការចូលរួមឲ្យបាន ច្រើន។




Metro

# ការប្រជុំនាពេលខាងមុខ

**Coordinating Committee**

> *ថ្ងៃពុធ ទី15 ខែមិថុនា ម៉ោង 3:30-5:00 ល្ងាច*

**គណៈកម្មាធិការដឹកនាំសហគមន៍**

> *ថ្ងៃព្រហស្បតិ៍ ទី23 ខែមិថុនា ម៉ោង 5-7 យប់*

**ក្រុមការងារផ្សេងៗ**

> **កិច្ចប្រជុំក្រុមការងាររថយន្តដឹកទំនិញមិនបញ្ចេញផ្សែងពុល #7**
> *ថ្ងៃអង្គារ ទី 21 ខែមិថុនា ម៉ោង 1 - 2:30 រសៀល*

> **ក្រុមការងារសមធម៌ #4**
> *ថ្ងៃព្រហស្បតិ៍ ទី30 ខែមិថុនា ម៉ោង 5-7 យប់*

**ក្រុមការងារ**

> **កិច្ចប្រជុំក្រុមការងារ #10**
> *ថ្ងៃចន្ទ ទី11 ខែកក្កដា ម៉ោង 5-7:30 យប់*

Metro

# វក្យាទំនាក់ទំនងជាមួយគម្រោងនេះ។

Michael Cano, *Executive Officer (Interim)*
*Countywide Planning & Development*
Metro
One Gateway Plaza, MS 99-13-1
Los Angeles, CA 90012

213.922.4710

*710corridor@metro.net*

*metro.net/projects/i-710-corridor*

*@metrolosangeles*

*losangelesmetro*

Metro

# សូមអរគុណសម្រាប់ការចូលរួមជាមួយពួកយើង!

Metro

# REFERENCE SLIDE

# ស្លាយឯកសារយោង

Metro

# សេចក្តីថ្លែងគោលការណ៍ដឹកនាំនិរន្តរភាពដែលបានដាក់ស្នើ

- ផែនការវិនិយោគតំបន់ខ្សែបន្ទាត់ផ្លូវ I-710 ភាគខាងត្បូង គឺមានមូលដ្ឋានគ្រឹះលើគោលការណ៍ដឹកនាំនិរន្តរភាព ៖ “ការអភិវឌ្ឍដែលបំពេញតាមតម្រូវការនាពេលបច្ចុប្បន្ន ដោយមិនធ្វើឱ្យប៉ះពាល់ដល់សមត្ថភាព របស់មនុស្សជំនាន់ ក្រោ យ ក្នុងការបំពេញតាមតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ”។
- *“ការប្តេជ្ញាចិត្តទៅលើនិរន្តរភាពគឺជាការបំពេញបាននូវតម្រូវការសង្គម និងសេដ្ឋកិច្ចជាមូលដ្ឋាន ទាំងនាពេលបច្ចុប្បន្ននិងអនាគត និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយទំនួលខុសត្រូវ ទាំងអស់នេះខណៈរក្សាបាន ឬកែលម្អសុខុមាលភាពបរិស្ថានដែលជីវិតពឹងផ្អែកលើ។”*

## និរន្តរភាពសេដ្ឋកិច្ច

- ផ្តោតលើការអនុវត្តដែលគាំទ្រការរីកចម្រើនផ្នែកសេដ្ឋកិច្ចរយៈពេលវែង ដោយមិនផ្តល់ផលប៉ះពាល់ជាអវិជ្ជមានលើទិដ្ឋភាពសង្គម បរិស្ថាន និងវប្បធម៌របស់សហគមន៍។

## និរន្តរភាពសង្គម

- ផ្តោតលើតម្រូវការសង្គមជាមូលដ្ឋានរបស់មនុស្ស រួមមានសុខភាពនិងសុខុមាលភាព ការអប់រំ កិត្តិយស សន្តិភាព និងយុត្តិធម៌។

## និរន្តរភាពបរិស្ថាន

- ផ្តីជាទំនួលខុសត្រូវក្នុងការថែរក្សាធនធានធម្មជាតិ និងការពារប្រព័ន្ធអេកូឡូស៊ីសកល ដើម្បីគាំពារសុខភាព និងសុខុមាលភាព នាពេលបច្ចុប្បន្ននិងអនាគត។

Metro